# កំណើនសេដ្ឋកិច្ចដ៏រឹងប៉ឹង និង ការកែលំអវិធីសាស្ត្រ រាយការណ៍: ការសើរើកែ តំរូវឡើងវិញនូវការប៉ាន់ស្មានក្នុងគណនីជាតិកម្ពុជា ឆ្នាំ២០០៥

*កញ្ញា អ៊ួច ច័ន្ទតារានី និងបណ្ឌិត Keith Carpenter ពិពណ៌នាពីលទ្ធផលគន្លឹះ និងបញ្ហាកើតឡើង បន្ទាប់ពីការចេញផ្សាយតួលេខប៉ាន់ស្មាននៃគណនីជាតិឆ្នាំ២០០៥ ដោយវិជ្ជាស្ថានជាតិស្ថិតិ នៅខែកក្កដា ឆ្នាំ២០០៦ ។ **

អត្ថបទនេះរៀបរៀងឡើងបន្ទាប់ពីវិជ្ជាស្ថានជាតិស្ថិតិ បានផ្សព្វផ្សាយនៅខែកក្កដា ២០០៦ នូវតួលេខប៉ាន់ស្មាននៃគណនីជាតិឆ្នាំ២០០៥ ។ អត្ថបទរៀបរាប់ពីចំនុចសំខាន់ៗខ្លះនៃការប៉ាន់ស្មានទាំងនោះ ព្រមទាំងបកស្រាយពីបញ្ហាមួយចំនួនដែលផុសឡើង ដូចជា អន្តរកម្មរវាងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងលទ្ធភាពកាត់បន្ថយភាពក្រីក្រ ការបញ្ចូលតួលេខសើរើកែតំរូវក្នុងគណនីជាតិទៅក្នុងបណ្ដាឆ្នាំកន្លងមក និងការធានាកិរិតសមត្ថភាព សំរាប់រក្សាគុណភាពបច្ចុប្បន្ននៃគណនីជាតិ ។ ការវិភាគស៊ីជំរៅពីតួលេខប៉ាន់ស្មាន នៃគណនីជាតិនឹងមានចុះផ្សាយក្នុងឯកសារផ្សេងៗទៀតរបស់ វបសអ ។

នៅប្រទេសកម្ពុជា គេប្រើប្រាស់បញ្ជីឈ្មោះជាក់លាក់សំរាប់វិស័យសេដ្ឋកិច្ចទាំងបី គឺមាន កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ដោយមិនប្រើពាក្យវិស័យទី១ វិស័យទី២ និងវិស័យទី៣ នោះទេ ។ អត្ថបទនេះប្រើប្រាស់បញ្ជីឈ្មោះរបស់កម្ពុជា ប៉ុន្តែប្រើពាក្យថា "អនុវិស័យ" សំរាប់សំគាល់សមាសភាគនានាដែលមាននៅក្នុងវិស័យនីមួយៗ ដើម្បីជៀសវាងការភាន់ច្រឡំគ្នារវាងវិស័យទាំងមូល និងសកម្មភាពជាក់លាក់នានាដែលមាននៅក្នុងវិស័យនីមួយៗ ។

## កំណើនទូទៅ

វិជ្ជាស្ថានជាតិស្ថិតិ (NIS) បានផ្សព្វផ្សាយនៅខែកក្កដា ២០០៦ នូវតួលេខប៉ាន់ស្មានដំបូងៗនៃគណនីជាតិសំរាប់ឆ្នាំ២០០៥ និងតួលេខប៉ាន់ស្មានសំរាប់ឆ្នាំ២០០១-២០០៤ ដែលបានសើរើកែតំរូវឡើងវិញ[១] ។ យោងតាម NIS សេដ្ឋកិច្ចកម្ពុជាកើនយ៉ាងច្រើននៅឆ្នាំ២០០៥ ។ ផសស ពិត គិតតាមថ្លៃថេរ

**តារាង ១. កំណើន ផសស លំអិតតាមវិស័យចំបងៗ (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| វិស័យ | 2004 | 2005 |
|---|---|---|
| **ផសស** | **10.0** | **13.4** |
| កសិកម្ម | 1.2 | 16.6 |
| ឧស្សាហកម្ម | 16.4 | 12.1 |
| សេវាកម្ម | 11.7 | 12.1 |

ឆ្នាំ២០០០ កើនបាន ១៣,៤% នៅឆ្នាំ២០០៥ ធៀបនឹងកំណើនកែតំរូវ ១០,០% នៅឆ្នាំ២០០៤ ។

កសិកម្ម ជាវិស័យមានចំណែកធំជាងគេ នៅក្នុងកំណើនឆ្នាំ២០០៥ ដោយកើនបាន ១៦,៦% នៅឆ្នាំ២០០៥ ធៀបនឹងអត្រាកំណើនកែតំរូវ ១,២% នៅឆ្នាំ២០០៤ ។ ប៉ុន្តែកំនើនក្នុងវិស័យឧស្សាហកម្ម បានថយចុះដោយមានកំរិត ១២,១% ធៀបនឹង ១៦,៤% នៅឆ្នាំ២០០៤ ។ វិស័យសេវាកម្ម កើនបាន ១២,១% ធៀបនឹងកំណើនកែតំរូវ ១១,៧% នៅឆ្នាំ២០០៤ ។

តួលេខដែលប៉ាន់ស្មានដំបូងៗ សំរាប់ឆ្នាំ២០០៥ មានចុះសង្ខេបនៅក្នុងតារាង ២ ។

## កំណើនក្នុងវិស័យកសិកម្ម

យោងតាម NIS ចំនុចគួរកត់សំគាល់ជាងគេនៅឆ្នាំ២០០៥ គឺកំណើនយ៉ាងច្រើនក្នុងវិស័យកសិកម្ម បើធៀបនឹងឆ្នាំ២០០៤ (តារាង៣) ដោយក្នុងនេះផលដំណាំមានចំណែកធំជាងគេ ។ ស្រូវដែលតំណាងឱ្យ ៤៨,៩% នៃតំលៃបន្ថែមដុលសំរាប់ផលដំណាំកសិកម្មគិតតាមថ្លៃថេរឆ្នាំ២០០០ បានកើនយ៉ាងខ្លាំងដល់ ៤៣,៥% នៅឆ្នាំ២០០៥ ធៀបនឹងការរួមចុះដល់ទៅ ១២,២% នៅឆ្នាំ២០០៤ ។ យោងតាម NIS សន្ទុះកំណើននេះបណ្ដាលមកពីធាតុអាកាសល្អ គួបផ្សំនឹងការកែលំអប្រព័ន្ធស្រោចស្រព ការពង្រីកផ្ទៃដីដាំដុះ និងកត្តាផ្សេងទៀត ដូចជា ការផ្លាស់ប្ដូរបច្ចេកទេស និងការផ្សព្វផ្សាយ

**តារាង ២. តួលេខប៉ាន់ស្មាននៃ ផសស ឆ្នាំ២០០៥**

| | រៀល | កំណើន គិតជារៀល | ដុល្លារ | កំណើន គិតជាដុល្លារ |
|---|---|---|---|---|
| ផសស ចារីក | 25,350ពាន់លាន | 19.9% | 6195លាន | 17.7% |
| ផសស ចារីក គិតក្នុង១នាក់ | 1.833លាន | 17.5% | 448 | 15.3% |
| ផសស ពិត | 21,812ពាន់លាន | 13.4% | 5,330លាន | 11.3% |
| ផសស ពិត គិតក្នុង១នាក់ | 1.577លាន | 11.1% | 385 | 9.0% |

* អ៊ួច ច័ន្ទតារានី គឺជាជំនួយការស្រាវជ្រាវនៅ វបសអ ហើយបច្ចុប្បន្នបានផ្អាកការងារទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅសាលាគោលនយោបាយសាធារណៈ លី ក្វាន់យូ នៅសាកលវិទ្យាល័យជាតិសិង្ហបុរី ។ Dr Keith Carpenter ជាទីប្រឹក្សាខាងស្រាវជ្រាវនៅ វបសអ ។

**តារាង ៣. កំណើន ផសស ក្នុងវិស័យកសិកម្ម (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| អនុវិស័យ | 2004 | 2005 |
|---|---|---|
| ផលដំណាំ | 1.7 | 28.0 |
| ស្រូវ | -12.2 | 43.5 |
| សត្វចិញ្ចឹម គិតទាំងមាន់ទា | 4.5 | 5.8 |
| ផលនេសាទ | -1.7 | 5.6 |
| ព្រៃឈើ និងការកាប់ឈើ | 2.2 | 5.4 |

បច្ចេកទេសកសិកម្មជាដើម[២] ។

ធាតុអាកាសអំណោយផលនៅឆ្នាំ២០០៥ បានជួយឱ្យផលស្រូវវស្សាកើនយ៉ាងច្រើនដល់ទៅ ៧៩% នៃផលស្រូវសរុប រឺកើន ៥១% ធៀបនឹងផលស្រូវឆ្នាំ២០០៤ ។ ភ្លៀងបានធ្លាក់ចុះចំពេលល្អក្នុងរយៈពេលដាំដុះ (ដើមរដូវវស្សា) នៅឆ្នាំ២០០៥ ថ្វីបើតំបន់ខ្លះជួបការរាំងស្ងួតនៅពាក់កណ្ដាលរដូវវស្សាក្ដី[៣] ។ ដោយមូលហេតុនេះ NIS ប៉ាន់ស្មានថា ៣១,១% នៃកំណើនផលស្រូវសរុបនៅឆ្នាំ២០០៥ ទទួលបានដោយសារធាតុអាកាសល្អ ។ ម្យ៉ាងទៀត យោងតាមរបាយការណ៍ក្រសួងកសិកម្ម គឺមានការវិនិយោគយ៉ាងច្រើនក្នុងការស្ដារជួសជុល និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការដាក់អនុវត្តន៍បច្ចេកទេសគ្រប់គ្រងទឹកកាន់តែប្រសើរឡើង ក្នុងប៉ុន្មានឆ្នាំកន្លងទៅ ។

យោងតាមទិន្នន័យទទួលបានពីក្រសួងកសិកម្ម កំណែលំអនេះ បានចូលរួមមួយចំណែកដល់កំណើន ២១% នៃផលស្រូវប្រាំងនៅឆ្នាំ២០០៥ និងរួមចំណែក ១,៣% ដល់កំណើនផលស្រូវសរុបនៅឆ្នាំ២០០៥ បើតាមការប៉ាន់ស្មានរបស់ NIS ។ លើសពីនេះទៅទៀតផ្ទៃដីដាំដុះស្រូវបានពង្រីក ២,៧% នៅឆ្នាំ២០០៥ ដោយសារដីខ្លះដែលនៅទំនេរចោលកាលពីឆ្នាំមុន បានយកមកដាំស្រូវនៅឆ្នាំ២០០៥ ហើយដីព្រៃខ្លះ ក៏ត្រូវបានកាប់រានយកមកដាំស្រូវដែរ ។

**តារាង ៤. កំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម (%) គិតតាមថ្លៃថេរឆ្នាំ២០០០**

| វិស័យ/អនុវិស័យ | 2004 | 2005 |
|---|---|---|
| **ឧស្សាហកម្ម** | | |
| កម្មន្តសាលកម្ម | 17.6 | 9.7 |
| *កាត់ដេរ* | *24.9* | *10.3* |
| សាងសង់ | 13.2 | 20.1 |
| **សេវាកម្ម** | | |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 23.4 | 17.3 |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | 7.5 | 13.1 |
| អចលនទ្រព្យ និងសេវាបំរើអាជីវកម្ម | 12.6 | 6.9 |
| **ពន្ធប្រយោល** | **21.4** | **11.4** |
| **កំណើន ផសស សរុប** | **10.0** | **13.4** |

## កំណើនក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម

អត្រាកំណើននៃអនុវិស័យសំខាន់ៗ នៅក្នុងវិស័យមិនមែនកសិកម្ម មានចុះក្នុងតារាង ៤ ។

កំណើនខាងកម្មន្តសាលធ្លាក់ចុះពី ១៧,៦% នៅឆ្នាំ២០០៤ ដល់ ៩,៧% នៅឆ្នាំ២០០៥ ដោយសារជាសំខាន់មកពីការធ្លាក់ចុះក្នុងឧស្សាហកម្មកាត់ដេរដែលមានអត្រាកំណើនពិត ថយចុះពី ២៤,៩% ដល់ ១០,៣%។ ផលិតផលខាងសាងសង់កើន ២០,១% នៅឆ្នាំ២០០៥ ធៀបនឹង ១៣,២% នៅឆ្នាំ២០០៤ ដោយសារជាសំខាន់មកពីកំណើនសកម្មភាពសាងសង់នៅភ្នំពេញដែលផុសចេញពីកំណើនដ៏ខ្ពស់ក្នុងសេដ្ឋកិច្ចទាំងមូល ។

## របាយសកម្មភាពសេដ្ឋកិច្ច

របាយសកម្មភាពសេដ្ឋកិច្ច មានចុះក្នុងតារាង ៥ ។

សេវាកម្មនៅតែជាវិស័យចំបងគេ ប៉ុន្តែបានថយចុះបន្តិចដោយសារការស្ទុះឡើងវិញនៃវិស័យកសិកម្មនៅឆ្នាំ២០០៥ ដូចមានបង្ហាញនៅក្នុងតួលេខកំណើន ។ តារាង៦ បង្ហាញពីអនុវិស័យសំខាន់ៗនៅក្នុងវិស័យនីមួយៗ ។

តារាង ៦ មិនបានបូកបញ្ចូលវិស័យ "ទេសចរណ៍" ទេ ពីព្រោះនៅក្នុងគណនីជាតិ គេមិនបានទទួលស្គាល់វាថាជាអនុវិស័យ ។ ក្នុងការប្រើប្រាស់ធម្មតា វិស័យ "ទេសចរណ៍" សំដៅដល់ទេសចរបរទេសចូលមកទស្សនាប្រទេសកម្ពុជា ដែលតែងប្រើប្រាស់សេវាដឹកជញ្ជូន សណ្ឋាគារ ភោជនីយដ្ឋាន សេវាផ្ទាល់ខ្លួនផ្សេងៗ និងទិញទំនិញនៅតាមហាងនានា ។ ចំណាយទាំងនេះត្រូវបានបូកបញ្ចូលក្នុងគណនីជាតិ ប៉ុន្តែយោងតាមរបាយការណ៍របស់ NIS គណនីជាតិមិនបានបែងចែក ចំណាយរបស់ទេសចរបរទេស ឱ្យដាច់ចេញពីចំណាយរបស់អ្នកដំណើរជានិវាសនជនកម្ពុជា ដែលកំពុងកើនឡើង រឺក៏ចំណាយរបស់និវាសនជនកម្ពុជា ដែលធ្វើដំណើរចុះឡើងដើម្បីធ្វើការរកស៊ីនៅក្នុងប្រទេសកម្ពុជាទេ ។

អនុវិស័យនីមួយៗដែលរៀបរាប់នៅក្នុងតារាង ៦ តំណាងឱ្យប្រហែល ៦៣% នៃសកម្មភាពសេដ្ឋកិច្ចសរុប ហើយភាគរយនេះ សឹងគ្មានការប្រែប្រួលក្នុង ២ឆ្នាំចុងក្រោយ ។ តារាងនេះបង្ហាញថា មាន ៣ អនុវិស័យបានគ្របដណ្ដប់លើសេដ្ឋកិច្ច (ផលដំណាំ ផលនេសាទ និងកាត់ដេរ) ដែលបច្ចុប្បន្នតំណាងឱ្យជិត ៤០% នៃសកម្មភាពសេដ្ឋកិច្ចសរុប ។ ផលដំណាំតំណាងឱ្យប្រហែល ៥០% នៃតំលៃបន្ថែមដុលក្នុងវិស័យកសិកម្ម ហើយស្រូវតំណាង

**តារាង ៥. របាយសកម្មភាពសេដ្ឋកិច្ច តាមវិស័យ (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| វិស័យ | 2004 | 2005 |
|---|---|---|
| កសិកម្ម | 30.6 | 31.4 |
| ឧស្សាហកម្ម | 27.3 | 27.0 |
| សេវាកម្ម | 36.7 | 36.2 |
| ពន្ធប្រយោល | 6.5 | 6.3 |
| កំណែតំរូវលើសេវាហិរញ្ញវត្ថុ | -1.0 | -1.0 |
| **សរុប** | **100** | **100** |

**តារាង ៦. ចំណែកអនុវិស័យសំខាន់ៗ នៅក្នុងវិស័យនីមួយៗ (%) គិតតាមថ្លៃថេរ ឆ្នាំ២០០០**

| វិស័យ/អនុវិស័យ | 2004 | 2005 |
|---|---|---|
| *កសិកម្ម* | ***30.6*** | ***31.4*** |
| ផលដំណាំ | 15.9 | 16.9 |
| ផលនេសាទ | 8.4 | 7.8 |
| *ឧស្សាហកម្ម* | ***27.3*** | ***27.0*** |
| កាត់ដេរ | 15.3 | 14.9 |
| *សេវាកម្ម* | ***36.7*** | ***36.2*** |
| ពាណិជ្ជកម្ម | 8.8 | 8.4 |
| អចលនទ្រព្យ និង សេវាបំរើអាជីវកម្ម | 7.0 | 6.6 |
| សេវាកម្មផ្សេងទៀត | 8.0 | 8.3 |

ឱ្យប្រហែលពាក់កណ្តាលនៃតំលៃបន្ថែមនេះ រឺប្រហែល ២៥% នៃតំលៃបន្ថែមខាងវិស័យកសិកម្ម ។

ជិតបីភាគបួននៃតំលៃបន្ថែមក្នុងវិស័យឧស្សាហកម្ម បានមកពីកម្មន្តសាល ហើយជាងពាក់កណ្តាលនៃតំលៃបន្ថែមផ្នែកឧស្សាហកម្ម បានមកពីខាងកាត់ដេរ ។ វិស័យសេវាកម្មរួមមាន ចំណូលពីទេសចរណ៍ ហើយសំខាន់គឺទេសចរបរទេស ប៉ុន្តែភាគច្រើននៃចំណូលក្នុងវិស័យនេះ បានមកពីសកម្មភាពក្នុងវិស័យមិនរៀបរយ ពោលគឺសកម្មភាពដែលនៅខាងក្រៅចរន្តធំនៃសេដ្ឋកិច្ច ។ វិស័យនេះ មិនមែនជាក្បាលម៉ាស៊ីនដ៏មានសន្ទុះដែលផ្តល់សេវាជឿនលឿន ដូចក្នុងបណ្តាប្រទេសមានឧស្សាហកម្មទំនើបៗនោះទេ ប៉ុន្តែភាគច្រើន គឺជាពួកឈ្មួញតូចតាចដែលរកស៊ីក្នុងវិស័យសេដ្ឋកិច្ចបន្ទាប់បន្សំប៉ុណ្ណោះ ។

បើសិនដកវិស័យសេវាកម្មចេញ គេអាចនិយាយថា សេដ្ឋកិច្ចកម្ពុជា ត្រូវបានគ្រប់ដណ្តប់ដោយអនុវិស័យនានាដែលពឹងផ្អែកលើធាតុអាកាស រឺមួយលើលទ្ធភាពមានទីផ្សារអំណោយផលនៅក្នុងប្រទេសអភិវឌ្ឍន៍ ព្រមទាំងសមត្ថភាពកាត់បន្ថយបន្ទុកចំណាយ ឱ្យទាបជាងប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតៗ ។ ដូច្នេះវាមិនមែនជាមូលដ្ឋានរឹងមាំ សំរាប់កសាងសេដ្ឋកិច្ចមួយដែលអាចលើកស្ទួយប្រជាជនជនបទក្នុងចំនួនច្រើនៗ ឱ្យបានរួចផុតពីភាពក្រីក្រនោះទេ ។ ប៉ុន្តែសំនួរថា តើមូលដ្ឋានដ៏សមស្របនោះជាអ្វី វាស្ថិតក្នុងការគិតគូរជាប់ជានិច្ចរបស់សេដ្ឋវិទូខាងអភិវឌ្ឍន៍ និងស្ថាប័នជាច្រើនដែលយកចិត្តទុកដាក់ពីការរីកចំរើនទៅអនាគតរបស់ប្រទេសកម្ពុជា ដូចជាវបសអ ជាដើម ។ ជាឧទាហរណ៍ សូមពិនិត្យពីបញ្ហានានាដែលធនាគារពិភពលោក បានធ្វើការស្ទាបស្ទង់មតិ ដូចមានចុះក្នុងឯកសារ *Cambodia: Halving poverty by 2015? (កម្ពុជា: កាត់បន្ថយភាពក្រីក្រ បានពាក់កណ្តាលនៅឆ្នាំ២០១៥?)*[៤] ។

## ការសើរើកែតំរូវលើគណនីជាតិ

ការសើរើកែតំរូវលើគណនីជាតិឆ្នាំ២០០៥ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការវាស់វែងសំខាន់ៗនៃសកម្មភាពសេដ្ឋកិច្ច ។ ការសើរើកែតំរូវ មានពីរប្រភេទធំៗ: ការពង្រីកដែនគ្របដណ្តប់ និងការកែលំអវិធីសាស្ត្រប្រមូលចងក្រងទិន្នន័យ ។ ការគ្របដណ្តប់ បានពង្រីកថែមទៀតតាមការដាក់បញ្ចូលកសិ-ពាណិជ្ជកម្ម ការយករ៉ែមាស ការរុករកប្រេងកាត ការផ្គត់ផ្គង់ឧស្ម័ន សកម្មភាពធានារ៉ាប់រង មីក្រូ-ហិរញ្ញវត្ថុ និងសកម្មភាពប្តូរប្រាក់ ។ ការគ្របដណ្តប់ ត្រូវបានកែលំអសំរាប់ការដឹកយកត្បូង ការដឹកជញ្ជូនទំនិញ ការថែទាំសុខភាពឯកជន និងអ្នកផ្តល់សេវាថែទាំសុខភាពឯកជន ។ បច្ចុប្បន្ន NIS ជឿជាក់ថា ក្រៅពីការផលិត និងជួញដូរគ្រឿងញៀនខុសច្បាប់ចេញ គណនីជាតិ បានគ្របដណ្តប់លើសកម្មភាពសេដ្ឋកិច្ចគ្រប់បែបនៅកម្ពុជា ។ នេះជាការជឿនលឿនមួយយ៉ាងធំ ហើយ NIS គួរទទួលបានការលើកសរសើរចំពោះលទ្ធផលដ៏សំខាន់នេះ ។

ការធ្វើកំណែលំអវិធីសាស្ត្រប្រមូលចងក្រងទិន្នន័យ រួមមានការស្វែងរកប្រភពកាន់តែសមស្របនិងត្រឹមត្រូវសំរាប់ថ្លៃទំនិញ ការកែលំអសន្ទស្សន៍បរិត្តផរណា (price deflators) សំរាប់អនុវិស័យមួយចំនួន ការប៉ាន់ស្មានឱ្យកាន់តែត្រឹមត្រូវ នូវចំណាយប្រើប្រាស់ចុងក្រោយក្នុងគ្រួសារ (HFCE) និងការសើរើកែតំរូវវិធីសាស្ត្រ ដើម្បីបញ្ចូលចំណាយលើបរិក្ខារជាប់លាប់ ។ ការផ្លាស់ប្តូរខ្លះ គឺជាលទ្ធផលនៃការដាក់បញ្ចូលនូវ ការផ្លាស់ប្តូរចំពោះលំនាំចំណាយ និងផលិតកម្ម ដែលបានរកឃើញតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤ ។ CSES នឹងក្លាយទៅជាអង្កេតធ្វើឡើងជាប្រចាំចាប់តាំងពីឆ្នាំ២០០៧ តទៅ គឺមិនមែនប្រាំឆ្នាំធ្វើម្តងនោះទេ ហើយគេរំពឹងថា វិធីសាស្ត្រប្រមូលចងក្រងទិន្នន័យ នឹងអាចវិវត្តបានកាន់តែស៊ីសង្វាក់គ្នាល្អជាមួយនឹងការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច ។ លទ្ធផលនៃ CSES 2004 បានប៉ះពាល់ជាពិសេសដល់ការប៉ាន់ស្មានពី HFCE និងការប្រើប្រាស់បរិក្ខារជាប់លាប់ ។ តួលេខប៉ាន់ស្មានធ្វើឡើងកាលពីមុនក្នុងគណនីជាតិ វាឈរលើការសន្មតថា ទំនិញជាប់លាប់ដែលនាំចូលត្រូវបានយកទៅប្រើប្រាស់នៅក្នុងផលិតកម្មឧស្សាហកម្មជាច្រើនប្រភេទ ។ CSES 2004 បង្ហាញថា អ្នកប្រើប្រាស់នៅទីក្រុង បានទិញទំនិញជាប់លាប់សំរាប់ប្រើប្រាស់ក្នុងគ្រួសារច្រើនជាងអ្វីដែលគេធ្លាប់បានគិតឃើញ ។ តួលេខប៉ាន់ស្មានចុងក្រោយលើ HFCE បានយកលទ្ធផលរកឃើញក្នុង CSES 2004 នេះមកប្រើប្រាស់ ហើយវានឹងបន្តជះឥទ្ធិពលទៅលើ ការប៉ាន់ស្មានក្នុងគណនីជាតិ នៅពេលអនាគតទៀតជាមិនខាន ។

ជាបន្ថែមពីលើ ការសើរើកែតំរូវដោយសារមានការផ្លាស់ប្តូរចំពោះការគ្របដណ្តប់ និងការប្រមូលចងក្រងទិន្នន័យ NIS ក៏បានធ្វើការផ្លាស់ប្តូរមួយចំនួនទាក់ទិននឹងប្រភពទិន្នន័យផងដែរ ក្នុងនេះ មានទាំងលទ្ធផលនៃ CSES 2004 ផង ។ លទ្ធផលបានពីការគន់គូរពិសេសលើកទី២ ស្តីពីប្រជាជនក៏បានដាក់បញ្ចូលទៅក្នុងការប៉ាន់ស្មានដែរ ។ ការគន់គូរពីប្រជាជនបានប៉ះពាល់ខ្លាំងជាងគេ ដល់បែបបទដែលលទ្ធផលបានពីគំរូតាង CSES អាចយកទៅប្រើប្រាស់ដើម្បីធ្វើការកំណត់តួលេខប៉ាន់ស្មាននៃធាតុចេញ និងចំណាយសំរាប់ប្រទេសកម្ពុជាទាំងមូល ។ ចំពោះទិន្នន័យសើរើកែតំរូវ គេក៏ទទួលបានពីក្រសួងជំនាញ និងធនាគារជាតិនៃកម្ពុជា មកដាក់បញ្ចូលនៅក្នុងគណនីជាតិដែរ ។ ទិន្នន័យសើរើកែតំរូវ ថែមទាំងមានបញ្ចូលនូវការសិក្សាពិសេសៗមួយចំនួនលើអនុវិស័យជាក់លាក់ ដូចជា វារីវប្បកម្មនេសាទសមុទ្រ សត្តឃាត និង កាស៊ីណូ ។ ដើម្បីធ្វើការប្រមូលទិន្នន័យសំរាប់គណនីជាតិ NIS ក៏បានធ្វើអង្កេតជាច្រើនដងមកហើយលើ អ្នកលក់ដុំ អ្នកលក់រាយ ផ្ទះសំណាក់ និងអាជីវករដឹកជញ្ជូន ដែលមាននៅក្នុងវិស័យមិនរៀបរយដែរ ។

## ការផ្ដល់មតិអំពី ការផ្លាស់ប្ដូរវិធីសាស្ត្រដើម្បីផ្សព្វផ្សាយ តួលេខសើរើកែតំរូវនៃគណនីជាតិ

កាលពីមុន NIS បានដាក់បញ្ចូលការផ្លាស់ប្ដូរក្នុងការគ្របដណ្ដប់ និងការប្រមូលចងក្រងទិន្នន័យ ទៅក្នុងតួលេខសើរើកែតំរូវនៃគណនីជាតិ នៅឆ្នាំមុនៗថយក្រោយមករហូតដល់ឆ្នាំ១៩៩៣ ។ ដោយមានការផ្ដល់មតិជំទាស់ពីអ្នកប្រើប្រាស់ទិន្នន័យ ជាពិសេសអ្នកប្រើប្រាស់ទិន្នន័យសំរាប់ធ្វើវិភាគពីមួយឆ្នាំទៅមួយឆ្នាំ NIS ក៏បានផ្លាស់ប្ដូររបៀបនេះចេញ ។ ដោយចាប់អនុវត្តពីត្រឹម តួលេខប៉ាន់ស្មានបច្ចុប្បន្ននៃគណនីជាតិនេះតទៅ កំរងទិន្នន័យនឹងត្រូវសើរើកែតំរូវ ដោយដាក់បញ្ចូលតួលេខកែតំរូវថយក្រោយតែត្រឹមឆ្នាំ២០០១ ។

គេអាចយល់បានពីវិធីធ្វើការសើរើកែតំរូវរបស់ NIS ប៉ុន្ដែរឿងតំរូវការធ្វើដូច្នេះ គឺជាចំងល់មួយ ។ គណនីជាតិមាន គោលដៅរាយការណ៍ឱ្យបានត្រឹមត្រូវ និងពិតប្រាកដជានិច្ច ។ បើសិនជាមានការរីកចំរើនខាងចំណេះដឹងអំពីដំណើរការសេដ្ឋកិច្ច ការរីកចំរើននេះគួរតែផ្សព្វផ្សាយឱ្យបានទំលំទូលាយ ដើម្បីជំរុញឱ្យមានការប្រើប្រាស់ទិន្នន័យល្អៗបំផុត ។ វាជាការមិនសមរម្យសោះ ដែលទៅធ្វើការរារាំង រឺបំភ្លេចចោលនូវកំណែលំអនានានៅក្នុងការគ្របដណ្ដប់ និងវិធីសាស្ត្រ ពីព្រោះតែរឿងនេះ វាអាចនាំឱ្យគំរូសេដ្ឋកិច្ចជាក់លាក់ណាមួយ ត្រូវតែធ្វើការប៉ាន់ស្មាន គិតគូរ រឺក៏កសាងឡើងវិញនោះ ។

គណនីជាតិ គឺជាតួលេខប៉ាន់ស្មាន ហើយនឹងនៅតែជាការប៉ាន់ស្មានដូច្នេះជារៀងរហូត ប៉ុន្ដែអ្នកប្រើប្រាស់ទិន្នន័យ គួរតែអាចរំពឹងថា វាជាការប៉ាន់ស្មានដ៏ល្អបំផុត ដែលធ្វើឡើងដោយអ្នកមានវិជ្ជាជីវៈ និងមានការយល់ដឹងអំពីបច្ចេកទេសដ៏ចាំបាច់នានា ។ តួលេខប៉ាន់ស្មាននៃគណនីជាតិ គឺជាការប៉ាន់ស្មាន "ជួរទី១" ដែលធ្វើឡើងមុនគេ ក្រោយពេលប្រមូលចងក្រងបាននូវទិន្នន័យសេដ្ឋកិច្ចដើម ។ គំរូនានាក៏ជាការប៉ាន់ស្មានដែរ ហើយវាពឹងផ្អែកលើទិន្នន័យដែលកសាងចេញពីតួលេខប៉ាន់ស្មាននៃគណនីជាតិ ដូច្នេះ វាស្ថិតនៅឆ្ងាយមួយដំណាក់ថែមទៀតអំពីទិន្នន័យដើម ។ តាមលក្ខណៈនេះ វាជាការប៉ាន់ស្មាន "ជួរទី២" ។

គំនិតដែលថា អ្នកកសាងគំរូក្នុងឋានៈជាអ្នកប៉ាន់ស្មាននៅជួរទី២ គួរមាន "សិទ្ធិវេតូ" ចំពោះលទ្ធផលការងាររបស់គណនេយ្យករជាតិដែលជាអ្នកប៉ាន់ស្មានជួរទី១ វាបង្ហាញថា អ្នកខ្លះអាចភ្លេចពីគោលដៅនៃគណនីជាតិដែលត្រូវធ្វើការស្វែងយល់ឱ្យបានកាន់តែប្រសើរអំពីរចនាសម្ព័ន្ធ និងដំណើរការនៃសេដ្ឋកិច្ច ។ ក្នុងករណីធ្ងន់ធ្ងរបំផុត គេអាចប្រមើលឃើញពីស្ថានភាពមួយដែលក្នុងនោះ កំណែលំអផ្សេងៗចំពោះគណនីជាតិ គឺមិនបានផ្សព្វផ្សាយទេ ពីព្រោះវាអាចប៉ះពាល់ដល់កំរងតួលេខប៉ាន់ស្មាន ក្នុងច្រើនឆ្នាំកន្លងមក ។ ស្ថានភាពនេះអាចនាំឱ្យមានការកសាងគំរូប៉ាន់ស្មានផ្សេងៗ ដែលមិនមានភាពត្រឹមត្រូវដូចគ្នា ហើយដែលនឹងក្លាយជាមូលដ្ឋាននៃការជួយមតិយោបល់មិនសមស្រប ព្រមទាំងធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជាជាទូទៅ ។

*មានការបារម្ភក្នុងរយៈពេលវែងថា តើការងារនឹងទៅជាយ៉ាងណានៅពេលសមាជិកកម្ពុជាចាកចេញពីក្រុម ទៅទទួលតួនាទីផ្សេងទៀត ។ គេសង្ឃឹមថា NIS មានផែនការបន្តតំណែង និងផែនការអន្តរកាលយ៉ាងសមស្រប ដើម្បីឱ្យអ្នកមកបន្តតំណែងអាចទទួលបានការផ្ទេរជំនាញនិងបទពិសោធន៍ពីក្រុមបច្ចុប្បន្ន ។ ទុនចំណេះដឹង ដែលបានកសាងឡើងយ៉ាងយកចិត្តទុកដាក់ក្នុងក្រុមគណនីជាតិ ត្រូវតែផ្ទេរទៅឱ្យពួកអ្នកវិជ្ជាជីវៈគណនីជាតិជំនាន់ក្រោយ នៅពេលមានការចាំបាច់ ។*

## ការសង្ឃឹមទៅអនាគត

ការប៉ាន់ស្មាននៅក្នុងគណនីជាតិឆ្នាំ២០០៥ សំរាប់ប្រទេសកម្ពុជា បានបន្តការងារកំណែលំអបច្ចេកទេសប៉ាន់ស្មាន ដែលគេអាចមើលឃើញយ៉ាងច្បាស់នៅក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ កំណែលំអនេះ មួយចំណែកបានមកពីការកសាងសមត្ថភាពនៅក្នុង NIS ដោយក្រុមបច្ចុប្បន្នបានធ្វើការរួមគ្នា ៥ ឆ្នាំមកហើយលើការប៉ាន់ស្មាន ។ ក្នុងមួយឆ្នាំៗ ក្រុមនេះអាចកែលំអគុណភាពតួលេខប៉ាន់ស្មានរបស់ខ្លួន ដោយផ្អែកលើបទពិសោធន៍ពីឆ្នាំមុន ។

ជារឿយៗ ការរីកចំរើន គឺជាដំណើរការកែលំអម្ដងបន្តិចៗ ដោយឈរលើគ្រឹះដ៏រឹងមាំនៃការងារបានធ្វើពីមុនមក និងមិនមែនជាដំណើរការបែបលោតផ្លោះនោះទេ ។ កំណែលំអដែលកំពុងអនុវត្ត នៅក្នុងគណនីជាតិកម្ពុជា គឺជាឧទាហរណ៍ដ៏ល្អមួយចំពោះកំណែទំរង់ម្ដងបន្តិចៗ ដែលបានផ្ដល់នូវផលប្រយោជន៍ដល់ប្រទេសកម្ពុជា ។ ក្រុមបច្ចុប្បន្ន រួមមានទីប្រឹក្សាស្ថិតិពហុវិស័យម្នាក់របស់ IMF និងសមភាគីកម្ពុជាមួយចំនួន ។ រយៈពេលដែលក្រុមគណនីជាតិ បានធ្វើការងារជាមួយគ្នា ជាកត្តាដ៏ល្អដែលនឹងជួយឱ្យមានការបន្តការងារដ៏រលូន នៅពេលទីប្រឹក្សា IMF ត្រូវចប់បេសកកម្មរបស់ខ្លួន ។ មានការបារម្ភក្នុងរយៈពេលវែងថា តើការងារនឹងទៅជាយ៉ាងណានៅក្រោយពេលសមាជិកកម្ពុជាចាកចេញពីក្រុម ហើយទៅទទួលតួនាទីផ្សេងទៀត ។ គេសង្ឃឹមថា NIS មានផែនការបន្តតំណែង និងផែនការអន្តរកាលយ៉ាងសមស្របផ្សេងទៀត ដើម្បីធ្វើឱ្យអ្នកមកបន្តតំណែងអាចទទួលបានការផ្ទេរជំនាញ និងបទពិសោធន៍ពីក្រុមបច្ចុប្បន្ន ។ ទុនចំណេះដឹងដែលបានកសាងឡើងយ៉ាងយកចិត្តទុកដាក់ក្នុងក្រុមគណនីជាតិ ត្រូវតែផ្ទេរទៅឱ្យពួកអ្នកជំនាន់ក្រោយដែលមានវិជ្ជាជីវៈខាងគណនីជាតិដែរ នៅពេលមានការចាំបាច់ ។

### កំណត់សំគាល់

១. ការបកស្រាយក្នុងអត្ថបទនេះ ផ្អែកលើឯកសារដែល NIS ចែកអោយនៅពេលផ្សព្វផ្សាយទិន្នន័យ ព្រមទាំងការបកស្រាយដែល NIS បានធ្វើឡើងនៅពេលនោះ ។ NIS បោះពុម្ពផ្សាយនូវតួលេខគណនីជាតិជារៀងរាល់ឆ្នាំ ហើយចំពោះតួលេខសំរាប់ឆ្នាំ២០០៥ កំពុងរៀបចំបោះពុម្ពផ្សាយ ។

២. ការបកស្រាយរបស់ NIS នាឱកាសរាយការណ៍ប្រាប់អ្នកប្រើប្រាស់ទិន្នន័យ នៅពេលផ្សព្វផ្សាយតួលេខប៉ាន់ស្មានឆ្នាំ២០០៥ ។

៣. របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ខែមីនា ឆ្នាំ២០០៦) ។

៤. Phnom Penh (World Bank) February 2006.